ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ១២៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍

- បានឃើញអនុក្រឹត្យលេខ២៦៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍ ដែលសរសេរជាអក្សរកាត់ថា **គ.ជ.អ.អ.** ដើម្បីដឹកនាំនិងជំរុញការអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍នៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## សមាសភាពនៃគ.ជ.អ.អ.

**មាត្រា២.-**

សមាសភាពនៃ**គ.ជ.អ.អ.**មានដូចខាងក្រោមៈ

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងបរិស្ថាន | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងទេសចរណ៍ ១រូប | សមាជិក |
| - អគ្គស្នងការនគរបាលជាតិ | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| - អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |

- អគ្គនាយកអគ្គិសនីកម្ពុជា សមាជិក
- អគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា សមាជិក
- ប្រធានគណៈកម្មាធិការអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍រាជធានី ខេត្ត សមាជិក
- ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា សមាជិក។

សមាសភាពជាក់ស្តែងនៃ**គ.ជ.អ.អ.**ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់គ.ជ.អ.អ.

**មាត្រា៣.-**

**គ.ជ.អ.អ.**ជាសេនាធិការជូនរាជរដ្ឋាភិបាលដែលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងធ្វើបច្ចុប្បន្នកម្មលើគោលនយោបាយនិងផែនការយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍
- រៀបចំលិខិតបទដ្ឋានគតិយុត្តចាំបាច់នានាដើម្បីគ្រប់គ្រងសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍
- ពិនិត្យ អនុម័ត និងគ្រប់គ្រងផែនការសកម្មភាពរបស់**គ.ជ.អ.អ.**
- ដឹកនាំ សម្របសម្រួល សហការ និងជំរុញការអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍ដើម្បីរួមចំណែកអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា
- ដឹកនាំ សម្របសម្រួល និងតាមដានការអនុវត្តគោលនយោបាយជាតិអេកូទេសចរណ៍(២០១៩-២០៣០) និងផែនការយុទ្ធសាស្ត្រនានាពាក់ព័ន្ធនឹងការជំរុញការអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍
- ពិនិត្យ វាយតម្លៃ និងទទួលស្គាល់សំណើសុំទទួលស្គាល់សហគមន៍ទេសចរណ៍និងអេកូទេសចរណ៍
- ពិនិត្យ វាយតម្លៃ និងអនុម័តគម្រោងនានាដែលអនុវត្តដោយសហគមន៍ អង្គការជាតិនិងអន្តរជាតិក្នុងសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍
- ពិនិត្យនិងតាមដានរាល់ប្រតិបត្តិការគម្រោងអភិវឌ្ឍន៍សហគមន៍ទេសចរណ៍និងអេកូទេសចរណ៍
- ដឹកនាំរៀបចំវេទិកាជាតិអេកូទេសចរណ៍ប្រចាំឆ្នាំនិងព្រឹត្តិការណ៍នានាក្នុងការជំរុញការអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍
- បញ្ជ្រាបការយល់ដឹងនិងផ្សព្វផ្សាយសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍
- ផ្តល់ជំនួយបច្ចេកទេសចាំបាច់ដល់សហគមន៍និងប្រតិបត្តិករក្នុងសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍
- ផ្តល់រង្វាន់ស្លាកសញ្ញាលើកទឹកចិត្តដល់ប្រតិបត្តិករទេសចរណ៍សហគមន៍និងអ្នកវិនិយោគក្នុងគម្រោងអភិវឌ្ឍន៍សហគមន៍ទេសចរណ៍និងអេកូទេសចរណ៍
- ធ្វើការសហការជាមួយក្រសួង ស្ថាប័ន អង្គការជាតិនិងអន្តរជាតិ ផ្នែកឯកជន និងភាគីពាក់ព័ន្ធទាំងអស់ដើម្បីសម្របសម្រួលការងារអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍កម្ពុជាឱ្យមានប្រសិទ្ធភាព
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនដោយរាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅនៃគ.ជ.អ.អ.

**មាត្រា៤.-**

**គ.ជ.អ.អ.**បើកកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមានឬមានធុរៈ អនុប្រធានអចិន្ត្រៃយ៍ឬអនុប្រធានត្រូវដឹកនាំកិច្ចប្រជុំ**គ.ជ.អ.អ.** តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**មាត្រា៥.-**

ប្រធាន**គ.ជ.អ.អ.**អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អ្នកឯកទេសឬផ្នែកឯកជនឱ្យចូលរួមប្រជុំពិគ្រោះយោបល់និងសិក្សាស្រាវជ្រាវលើរាល់ការងារទាំងឡាយដែលទាក់ទងនឹង**គ.ជ.អ.អ.**។

**មាត្រា៦.-**

**គ.ជ.អ.អ.**មានសិទ្ធិបង្កើតអនុគណៈកម្មការនិងក្រុមការងារបច្ចេកទេសតាមការចាំបាច់ក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍ ដែលត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន**គ.ជ.អ.អ.** ។

**គ.ជ.អ.អ.**ត្រូវបង្កើតគណៈកម្មាធិការអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍រាជធានី ខេត្ត ដែលត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន**គ.ជ.អ.អ.**។

**មាត្រា៧.-**

**គ.ជ.អ.អ.**មានលេខាធិការដ្ឋានមួយនៅក្រសួងទេសចរណ៍។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន**គ.ជ.អ.អ.**។

**មាត្រា៨.-**

**គ.ជ.អ.អ.**មានត្រាដោយឡែករបស់ខ្លួន ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី៥
## ប្រភពធនធានរបស់គ.ជ.អ.អ.

**មាត្រា៩.-**

ការចំណាយសម្រាប់កិច្ចដំណើរការ**គ.ជ.អ.អ.**ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងទេសចរណ៍។

**គ.ជ.អ.អ.**មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់នូវធនធាននិងមូលនិធិដែលបានមកពីប្រភពស្របច្បាប់ផ្សេងៗទៀតតាមនីតិវិធីច្បាប់ជាធរមាន សម្រាប់កិច្ចដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា១០.-**

រាល់លិខិតបទដ្ឋានគតិយុត្តទាំងឡាយណាដែលពាក់ព័ន្ធនឹងក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍ដែលមានមុនអនុក្រឹត្យនេះ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមអនុក្រឹត្យនេះ។



៣៧៤

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១១.-**

សេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលលេខ១០០ សសរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ ស្ដីពីការបង្កើតក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍ សេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលលេខ១១៣ សសរ ចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០១៩ ស្ដីពីការកែសម្រួលសមាសភាពនៃក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៦រោច ខែ ទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា ១៣៨

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**ថោង ខុន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ.១២៥..អនក្រ.បក ចុះថ្ងៃទី..៣០..ខែ...កក្កដា..ឆ្នាំ២០២១

# គំរូត្រាគណៈកម្មាធិការជាតិគ្រប់គ្រង
# និងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍

